**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
លេខៈ ០៤២/២០ ន.ផ.ទ./ក.អ.ជ

ថ្ងៃសុក្រ ១២ កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ ៖** របាយការណ៍វឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២០ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ។

សូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបអំពីរបាយការណ៍វឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២០ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈដូចខាងក្រោម៖

## ១. ស្ថានភាពមន្ត្រីរាជការ

- ចំនួនមន្ត្រីរាជការសរុប ៤៧ នាក់ ស្ត្រី ១១ នាក់(ក្នុងនោះមន្ត្រីជាប់កិច្ចសន្យា ០១ រូប )
- ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអនុប្រធាន ០៧ រូប (ស្ត្រី០២រូប)
- មន្ត្រីសហការជាមួយគម្រោងមានដូចខាងក្រោម៖

| **ល.រ** | **ឈ្មោះ** | **ភេទ** | **មុខងារ** | **គម្រោងកម្មវិធី** |
|---|---|---|---|---|
| ១ | ស្រ៊ន់ ពិធូ | ប | អនុប្រធាននាយកដ្ឋាន | គម្រោង TSLDP និង RRIP |
| ២ | ទាង ឆាយហៀង | ប | អនុប្រធាននាយកដ្ឋាន | គម្រោង CSADRMP |
| ៣ | នួន មុនីចិន្តា | ស | អនុប្រធាននាយកដ្ឋាន | គម្រោង IFAD |
| ៤ | សួស បូរិន្ទសក្តិ | ប | ប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៥ | ហេង ស្រីស្រស់ | ស | ប្រធានការិយាល័យ | គម្រោង CSADRMP |
| ៦ | ហ៊ឹម សួរជាតិ | ប | អនុប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៧ | គង់ សោភា | ស | អនុប្រធានការិយាល័យ | គម្រោង CSADRMP |

## ២. របាយការណ៍សម្រាប់ថ្នាក់ដឹកនាំនាយកដ្ឋាន

- ត្រួតពិនិត្យមើលឡើងវិញផែនការថវិកាឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ជួបពិភាក្សាជាមួយអង្គការ Caritas Cambodia ពីការបន្តរៀបចំផែនការ ៥ ឆ្នាំបន្ត
- ប្រជុំបូកសរុបលទ្ធផលការងារខែកុម្ភៈ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- ចូលរួមផ្សព្វផ្សាយលទ្ធផលសន្និបាតរបស់ក្រសួងនៅខេត្តកែប និងខេត្តព្រះសីហនុ

- រៀបចំកិច្ចប្រជុំប្រមូលទិន្នន័យស្តីពីកម្រងសេវាសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំជាមួយលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងចំនួន ០២លើក
- ជួបពិភាក្សាជាមួយតំណាង ADB និង EU លើការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី ការអនុវត្តផែនការ និងរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង
- ពិនិត្យ កែសម្រួល និងផ្តល់យោបល់លើឯកសារផែនការសកម្មភាព ASEAN-CANADA ដោយបានបន្ថែមសកម្មភាពចំនួន ០៣ ស្តីពីការអភិវឌ្ឍជនបទចូលក្នុងនោះ
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅស្ថិតិស្តីពីទំនាក់ទំនង ASEAN-CHINA ឆ្នាំ២០១៨
- រៀបចំរបាយការណ៍កិច្ចសហប្រតិបត្តិការ ទ្វេភាគី CAMBODIA-BANGLADESH ។
- ចូលរួមប្រជុំនៅក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជា (CDC) ស្តីពីការរៀបចំគម្រោងស្នើសុំជំនួយភ្នាក់ងារសហប្រតិបត្តិការកម្ពុជា ថៃឡង់ដ៍ ( Thai International Cooperation Agency) TICA
- រៀបចំគម្រោងស្នើសុំកិច្ចសហប្រតិបត្តិការជាមួយសាធារណៈរដ្ឋឆែក តាមរយៈក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កម្ពុជា (CDC)
- រៀបចំគម្រោងមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ កូរ៉េ (MKCF) តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១ -២០២៣ របស់ក្រសួង
- ពិនិត្យមើលរបាយការណ៍ក្រសួងត្រីមាសទី១ ឆ្នាំ២០២០
- ពិនិត្យសំណើសុំគោលការណ៍ រៀបចំសិក្ខាសាលារៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាកម្មវិធីឆ្នាំ២០២១ របស់ក្រសួងដែលរៀបចំដោយការិយាល័យផែនការ ស្ថិតិ
- រៀបចំគម្រោងសំណើទៅមេគង្គឡានឆាង សម្រាប់ឆ្នាំ២០២១
- រៀបចំតារាងតាមដានការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីតាមខែនីមួយៗ
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងដោយបានបញ្ចូលគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល គម្រោងវិនិយោគថវិការដ្ឋ គម្រោងវិនិយោគហិរញ្ញប្បទានដៃគូ បញ្ហាភាពក្រីក្រ និងយេនឌ័រចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល
- បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពផែនការថវិកាឆ្នាំ ២០២១ របស់ក្រសួងដើម្បីត្រៀមលក្ខណៈចូលរួមចរចាកញ្ចប់ថវិកាប្រចាំឆ្នាំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍សមិទ្ធកម្មថវិកាកម្មវិធីប្រចាំឆមាសទី១ ឆ្នាំ២០២០
- ចូលរួមប្រជុំត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ៣. សកម្មភាពការងារជំនាញ ការិយាល័យជំនាញទាំង ០៥ មានសកម្មភាពដូចខាងក្រោម ៖

#### ៣.១ ការិយាល័យកិច្ចការទូទៅ

- បានទទួលលិខិតចូលទូទៅចំនួន ១៤២ ច្បាប់
- បានទទួលលិខិតចូលក្នុងអង្គភាពចំនួន ៧២ ច្បាប់
- បានទទួលចូលក្រៅក្រសួងចំនួន ៧០ ច្បាប់
- លិខិតចេញទូទៅចំនួន ៧៩ ច្បាប់
- លិខិតបញ្ជូនចំនួន ០៨ ច្បាប់
- លិខិតបេសកកម្មចំនួន ៣៦ ច្បាប់
- លិខិតអញ្ជើញចំនួន ០៦ ច្បាប់
- លិខិតបង្គាប់ការចំនួន ០៣ ច្បាប់
- លិខិតសុំច្បាប់ចំនួន ០២ ច្បាប់
- លិខិតប្រកាសចំនួន ០១ ច្បាប់
- គ្រប់គ្រងវត្តមានប្រចាំខែរបស់មន្ត្រីរាជការ ។

**៣.២ ការិយាល័យផែនការ និងស្ថិតិ**

- រៀបចំសិក្ខាសាលាស្តីពីកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ឆ្នាំ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមអនឡាញនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការថវិកាកម្មវិធីឆ្នាំ២០២១ស្របតាមរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារ ហ៊ីម៉ាឡៃរី រាជធានីភ្នំពេញ
- រៀបចំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងផែនការថវិកាកម្មវិធីឆ្នាំ ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្តទាំង ២៥
- ចូលរួមសិក្ខាសាលាអន្តរក្រសួងស្តីពីការងារផែនការ និងស្ថិតិបានចំនួន ០៦ លើក
- ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំលើការងារកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) បានចំនួន ០៥ លើក នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំនៅទីស្តីការក្រសួង បានចំនួន ០៣ លើក
- ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំបូកសរុប និងពិភាក្សាលទ្ធផល នៃដំណើរបេសកកម្មក្រុមជំនាញការរបស់ EU ស្តីពីការវិភាគពីសមានគតិភាពរវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសម្របសម្រួលសិក្ខាសាលាពង្រឹងសមត្ថភាពតាមតំបន់ ស្តីពីការសរសេររបាយការណ៍ទិន្នន័យសម្រាប់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទ នៅខេត្តមណ្ឌលគិរី តាកែវ និងខេត្តបាត់ដំបង ។

**៣.៣ ការិយាល័យតាមដាន និងវាយតម្លៃ**

- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០៥ គឺ ខេត្តសៀមរាប កំពង់ធំ ស្ទឹងត្រែង បន្ទាយមានជ័យ ប៉ៃលិន កំពង់ធំ និងខេត្តព្រះវិហារ
- ប្រមូលផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងបញ្ចូលទិន្នន័យក្នុងតារាងតាមដាន
- ពិនិត្យ និងប្រមូលរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលក្នុងការអនុវត្តថវិកាកម្មវិធីក្នុងឆមាសទី១ ឆ្នាំ២០២០ ។

## ៣.៤ ការិយាល័យបច្ចេកវិទ្យាព័ត៌មាន

- ដំឡើង និងភ្ជាប់បណ្តាញ Internet ថ្មីល្បឿន 80Mpbs ពីក្រុមហ៊ុន SINET សម្រាប់ខុទ្ទកាល័យដែលត្រូវបានផ្លាស់ប្តូរពីបណ្តាញ ចាស់របស់ក្រុមហ៊ុន EZECOM ដែលមានល្បឿនតែ 4Mpbs
- ដំឡើង និងភ្ជាប់បណ្តាញ Internet ទៅអគារថ្មីជាន់ទី៤ បានចំនួន ០២ បន្ទប់
- ដំឡើង និងភ្ជាប់ទូរទស្សន៍មើលកាមេរ៉ាសុវត្ថិភាពចូលបន្ទប់ខុទ្ទកាល័យបានចំនួន ០៣ គ្រឿង
- ដំឡើងកម្មវិធីកាមេរ៉ាសុវត្ថិភាពតាមទូរស័ព្ទដៃជូនមន្ត្រីខុទ្ទកាល័យបាន ០៣ រូប
- ដំណើរការកែលម្អ និងផ្សព្វផ្សាយ Facebook Page ផ្លូវការរបស់ក្រសួងទទួលបានការ Like បន្ថែម ចំនួន ៣៣០០ Likes
- ដំណើរការ Upgrade Security plugin និង Core Security សម្រាប់គេហទំព័រក្រសួងបានសរុប ១២០ minor security និង ៣០ Major Core Security Updates
- ជួសជុលកុំព្យូទ័រជូនមន្ត្រីក្នុងក្រសួងបានចំនួន ០៧ គ្រឿង
- ត្រួតពិនិត្យ និងដោះស្រាយបញ្ហា Printers របស់នាយកដ្ឋាននានាក្នុងក្រសួងបានចំនួន ៤៥ ដង
- ត្រួតពិនិត្យ និងដោះស្រាយបញ្ហា Network/Internet ជូននាយកដ្ឋាននានាបាន ៤៧ ដង
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ។

## ៣.៥ ការិយាល័យអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ

- បានផ្តល់សំណើសុំហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០៦ លិខិត
- បានផ្តល់សំណើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងគម្រោង រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០១ លិខិត
- បានផ្តល់សំណើសុំហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០១ លិខិត។
- បានផ្តល់សំណើសុំបន្តអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានចំនួន ០២ លិខិត
- បានផ្តល់លិខិតសុំអន្តរាគមន៍ដើម្បីនាំចូលរថយន្តថ្មីចំនួន ០១ លិខិត
- បានផ្តល់សំណើសុំអន្តរាគមន៍ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់រថយន្ត និង

ទោចក្រយានយន្ត របស់អង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០៤ លិខិត

- បានផ្តល់សំណើសុំផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាព នៃកិច្ចសហប្រតិបត្តិការ អាស៊ាន-កាណាដា និងអាស៊ាន-សហរដ្ឋអាមេរិក ឆ្នាំ២០២១-២០១៥
- បានផ្តល់លិខិតគាំទ្ររបស់ក្រសួងអភិវឌ្ឍន៍ស្តីពីការទទួលជំនួយពីសប្បុរសជនក្នុង និងក្រៅប្រទេសរបស់សមាគមន៍សម្របសម្រួល និងអភិវឌ្ឍន៍សង្គម
- បានផ្តល់សំណើអន្តរាគមន៍ដើម្បីនាំចូលកាដូសម្រាប់បើកជូនកុមារចំនួន០២កុងតឺន័រ មាន៩៦០ កាតុង និងមានទម្ងន់សរុប ២២,៣៦៨ គីឡូក្រាម
- បានផ្តល់សំណើសុំគោលការណ៍ប្រជុំផ្សព្វផ្សាយនិងណែនាំអំពីសំណើគម្រោងហិរញ្ញប្បទានពីរដ្ឋាភិបាលសាធារណរដ្ឋឆែក សម្រាប់ឆ្នាំសារពើពន្ធ២០២០
- ប្រមូលរបាយការណ៍ត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០២០ របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆមាសទី១ របស់ក្រសួង
- បានចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ធំ បន្ទាយមានជ័យ ក្រចេះ រតនគិរី (២ដង) ខេត្តមណ្ឌលគិរី និងខេត្តសៀមរាប (២ដង)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

បានឃើញ និង ឯកភាព
សូមគោរពជូន **ឯកឧត្តមរដ្ឋលេខាធិការ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
**ប្រធាននាយកដ្ឋាន**

ម៉ា សុវណ្ណា

អ្នកធ្វើរបាយការណ៍

តុន សុវណ្ណារ័ត្ន

ថ្ងៃ អង្គារ ៨ កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២០
**បានឃើញ និងឯកភាព**
សូមគោរពជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
**រដ្ឋលេខាធិការ**

សុខ សារាវុឌ្ឍ

បានឃើញ
29.07.2020

ចម្លងជូនៈ
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
-ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
-ឯកឧត្តមអនុរដ្ឋលេខាទទួលបន្ទុក
-ឯកឧត្តមអគ្គនាយក
"ដើម្បីជូនជ្រាប
-ឯកសារ-កាលប្បវត្តិ